# San Diego Unified School District Fact Sheet

## ការពិនិត្យមើលពត៌មាននៅតាមសាលារៀនប្រចាំទីក្រុង San Diego

សាលារៀនប្រចាំទីក្រុង San Diego បំរើសិស្សចំនួនជាង១៥០០០០នាក់ ចាប់ពីថ្នាក់ មត្តេយ្យដ្ឋានដល់សិស្សថ្នាក់ទី ១២។ នៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ១៨៥៤ ក្រសួងអប់រំប្រចាំក្រុងបានសាងសង់ឡើងដោយមានតែអាគារសាលារៀនតូចមួយ ហើយមានតែគ្រូម្នាក់បំរើសិស្ស ហើយក្នុងពេលនេះក្រសួងអប់រំរបស់យើងគឺជាក្រសួងអប់រំធំលេខពីរក្នុងរដ្ឋ California នេះ។

បេសកកម្មរបស់ក្រសួងអប់រំ San Diego គឺ:

- បង្កើនការសិក្សាសិស្សអោយបានខ្ពស់
- ផ្តល់សន្តិសុខ, រក្សារអាគារសាលារៀន និងមានសណ្តាប់ធ្នាប់ល្អ
- ពង្រឹងការទាក់ទងមាតាបិតា, សហគមន៍, ហាងជំនួញទូទៅ ព្រមទាំងគាំទ្រការអប់រំសិស្សឲ្យបានខ្ពស់
- បង្កើនការលើកទឹកចិត្តបុគ្គលិកការងារឲ្យបានខ្ពស់
- រក្សារថវិការសំរាប់ដើម្បីបំរើសាលារៀនរបស់យើងឲ្យបានគ្រប់គ្រាន់

លោកបណ្ឌិត Carl Cohn ត្រូវបានជ្រើសរើសជាអគ្គស្នងការអប់រំពីខែ តុលា ២០០៥។ ក្រសួងអប់រំប្រចាំក្រុងមានគណៈកម្មការចំនួនប្រាំរូប - គណៈកម្មការម្នាក់ៗអាចប្រតិបត្តិកិច្ចការបាន បួនឆ្នាំ:

| | |
|---|---|
| Mitz Lee, គ្រប់គ្រងផ្នែក A: | ផុតអាណត្តិនៅឆ្នាំ ២០០៨ |
| Katherine Nakamura, (ប្រធាន) គ្រប់គ្រងផ្នែក B: | ផុតអាណត្តិនៅឆ្នាំ ២០១០ |
| John de Beck, (អនុប្រធាន) គ្រប់គ្រងផ្នែក C: | ផុតអាណត្តិនៅឆ្នាំ ២០១០ |
| Luis Acle, គ្រប់គ្រងផ្នែក D: | ផុតអាណត្តិនៅឆ្នាំ ២០០៨ |
| Shelia Jackson, គ្រប់គ្រងផ្នែក E: | ផុតអាណត្តិនៅឆ្នាំ ២០០៨ |

ក្រសួងអប់រំប្រចាំទីក្រុងមានទំហំដីជាង ២០០ម៉ាយការ៉េ នឹងរួមនឹងសាលារៀនចំនួន ២២១ ហើយបែងចែងចេញជាប្រាំផ្នែក។ ផ្នែកនិមួយៗមានសាលាបឋមសិក្សាចំនួន ២៥សាលា ហើយនៅក្បែរសាលាអនុវិទ្យាល័យ ហើយគ្រប់គ្រងដោយអគ្គស្នងការប្រចាំតំបន់នោះ។ សាលាវិទ្យាល័យចំនួន ២៩សាលានៅក្នុក្រសួងអប់រំប្រចាំក្រុងគ្រប់គ្រងដោយអគ្គស្នងការអប់រំរង។

នៅឆ្នាំ ១៩៩៨ ប្រជាជន San Diego ប្រជាជនចំនួន៧៨ភាគរយបានបោះឆ្នោតយល់ព្រមឲ្យចំណាយថវិការចំនួន១.៥១កោដិដុល្លារ ដើម្បីជុសជួលសាលារៀនចំនួន ១៦១សាលារៀន និងសង់សាលារៀនថ្មីចំនួន១២។ នៅឆ្នាំ ២០០៥ ច្បាប់ MM បានទទួលសញ្ញាប័ត្រលើកទឹកចិត្តពីក្រសួងពន្ធដារប្រចាំស្រុក San Diego County Taxpayers Association (SDCTA) - វាជាកិត្តយសដ៏ខ្ពស់សំរាប់កម្មវិធីប្រចាំស្រុកដែលបញ្ជាក់អំពីការប្រើប្រាស់ថវិការពន្ធដារនេះ។

នេះជាគន្លឹះដែលធ្វើឲ្យក្រសួងអប់រំប្រចាំក្រុងទទួលជោគជ័យបានគឺ រួមសហការជាមួយម្ចាស់ហាងជំនួញ, ប្រធានសហគមន៍និងបុគ្គលិកស្ម័គ្រចិត្តបំរើ ព្រមទាំងនិស្សិតមហាវិទ្យាល័យនិងសាកលវិទ្យាល័យ។អ្នកដែលចូលរួមជាដៃគូជាមួយក្រសួងអប់រំមានចំនួន ១៤០០ដូចជា ហាងជំនួញ, អង្គការសហគមន៍។ ឆ្នាំសិក្សា ២០០៦-០៧ ក្រុមដែលចូលរួមជាដៃគូនេះបានគិតជាថវិការជាងមានតម្លៃ ៥.៦លានដុល្លារ និងថវិការនិងសម្ភារៈ និងការបំរើ។ ក្រសួងអប់រំទទួលផលប្រយោជន៍ពីបុគ្គលិកស្ម័គ្រចិត្តបំរើជួយចំនួន២៦០០០នាក់។ ឆ្នាំ ២០០៦-០៧ បុគ្គលិកស្ម័គ្រចិត្តបំរើចំនួនជាង៩៩០០០០ម៉ោងគិតជាថវិការ១៨លានដុល្លារ (យោងទៅតាមប្រាក់ម៉ោងបុគ្គលិកធ្វើការគឺ ១៨.៧៧ដុល្លារ ក្នុងមួយម៉ោង ធ្វើឡើងដោយ Independent Sector, Washington, D.C.)។

### សង្ខេប

- ❖ សិស្សចំនួន១៣៥០៥៣នាក់ (ថ្នាក់មុន - K -១២)
- ❖ ក្រសួងអប់រំប្រចាំទីក្រុង San Diego ជាក្រសួងអប់រំធំលេខ ពីរក្នុងរដ្ឋ California
- ❖ ក្រសួងអប់រំប្រចាំទីក្រុង San Diego ជាក្រសួងអប់រំធំលេខ ប្រាំបី ក្នុងសហរដ្ឋ
- ❖ បុគ្គលិកមានសញ្ញាប័ត្រចំនួន
- ❖ បុគ្គលិកមិនមានសញ្ញាប័ត្រចំនួន ៨១១៥នាក់
- ❖ សរុបចំនួន១៥១១២បុគ្គលិកការងារស្មើនឹងពេញម៉ោង
- ❖ សរុបបុគ្គលិកការងារ ២៤០០៤នាក់ (រួមនឹងគ្រូធ្វើការប្រចាំម៉ោង និងគ្រូជំនួយ)
- ❖ មានមណ្ឌលអប់រំចំនួន សរុប ២២១កន្លែង
  - បឋមសិក្សាចំនួន ១១៨
  - អនុវិទ្យាល័យ ចំនួន ២៤
  - វិទ្យាល័យចំនួន ២៩
  - សាលាខុសពីធម្មតាចំនួន ១៥
  - សាលា Charter ចំនួន ៣៥
- ❖ សិស្សមានសញ្ជាតិចំរុះ (សិស្ស):
  - ៤៤.៤ភាគរយ ជាសិស្សស្ពែនីស
  - ២៥.៣ភាគរយ ជាសិស្សស្បែកស
  - ១៣.៥ភាគរយ ជាសិស្សអាមេរិកាំងស្បែកខ្មៅ
  - ៦.៦ភាគរយ ជាសិស្សភីលីពីន
  - ៥.២ភាគរយ ជាសិស្សឥណ្ឌូចិន
  - ៣.៥ភាគរយ ជាសិស្សអាស៊ី
  - .៥៥ភាគរយ ជាសិស្សអ្នកស្រុកដើមអាមេរិកាំង
- ❖ ចំនួនសិស្សចំរុះមានដូចជា:
  - សិស្សរៀន អង់គ្លេស ២៩.៥ភាគរយ
  - សិស្សទទួលអាហារមិនបាច់បង់ប្រាក់ ឬបង់តែបន្តិចបន្តួចចំនួន ៥៦.៩ភាគរយ
- ❖ សិស្សចំនួនប្រមាណ ១៦៤១៨នាក់ ចូលរៀនក្នុងកម្មវិធីពិសេស
- ❖ សិស្សចំនួនប្រមាណ១០០០០នាក់មកពីគ្រួសារកងទ័ព
- ❖ សិស្សចំនួនជាង ២២៥០០នាក់ ចូលរួមសិក្សាក្នុងកម្មវិធី Gifted and Talented Education
- ❖ ថវិការចំនួន ២.២កោដិដុល្លារ ត្រូវបានចំណាយលើក្រសួងអប់រំជាប្រចាំឆ្នាំ

ទាក់ទងពត៌មាន: ក្រសួងផ្នែកប្រស្រ័យទាក់ទង (៦១៩) ៧២៥-៥៥៧៨

www.sandi.net
Revised 12/12/07



San Diego Unified School Distrct at a Glance. Cambodian.